ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**<u>នាយកដ្ឋានព័ត៌មាន</u>**

## សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យ
## ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១. ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ មានការសោកស្តាយយ៉ាងខ្លាំង ពេលបានទទួលព័ត៌មានថា សភាតំណាងរាស្ត្រសហរដ្ឋអាមេរិក ទើបបានអនុម័ត «ច្បាប់ប្រជាធិបតេយ្យកម្ពុជាឆ្នាំ ២០១៩ - Cambodia Democracy Act of 2019» ។

២. អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្តែងការខកចិត្តយ៉ាងខ្លាំងចំពោះខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះ ហើយសូមធ្វើការបដិសេធយ៉ាងដាច់អហង្កានូវការចោទប្រកាន់ដោយគ្មានមូលដ្ឋានប្រឆាំងនឹងរាជរដ្ឋាភិបាលកម្ពុជា ដោយផ្អែកទៅលើព័ត៌មានបំភ្លៃ លំអៀង និងព័ត៌មានចាស់ហួសសម័យ ដោយសារតែហេតុផលនយោបាយ និងស្តង់ដារពីរ។ ក្នុងន័យនេះ អ្នកនាំពាក្យក្រសួងមានកាតព្វកិច្ចផ្តល់នូវការបកស្រាយបំភ្លឺដូចតទៅ៖

- សេចក្តីព្រាងច្បាប់នេះ ចាប់ផ្តើមដោយលើកឡើងថា **សម្តេចតេជោ ហ៊ុន សែន** គឺជាមេដឹកនាំដែលបានកាន់តំណែងយូរជាងគេបំផុតនៅអាស៊ីអាគ្នេយ៍។ ការកាន់តំណែងយូរដូច្នេះ មិនមែនមិនដែលមាននៅក្នុងបណ្តាប្រទេស ដែលប្រកាន់យកនូវប្រព័ន្ធនយោបាយបែបសភានិយមនៅតាមតំបន់នានានោះឡើយ។ ទាំងរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់អាណត្តិរបស់នាយករដ្ឋមន្ត្រីនោះទេ ដរាបណាគណបក្សរបស់ឥស្សរៈជនរូបនោះទទួលបានការគាំទ្រភាគច្រើនពីអ្នកបោះឆ្នោត ដែលអនុវត្តសិទ្ធិនយោបាយរបស់ខ្លួនដោយសេរី នៅក្នុងការបោះឆ្នោតជាទៀងទាត់ ក្រោមការឃ្លាំមើលពីអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ។ អាស្រ័យហេតុនេះ ការជាប់ឆ្នោតសារជាថ្មីឡើងវិញ ពុំមែនមានន័យថាគ្មានប្រជាធិបតេយ្យនោះទេ ហើយក៏មិនមែនជាបទល្មើសនោះដែរ។



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

- ការបដិសេធមិនទទួលស្គាល់ភាពស្របច្បាប់នៃការបោះឆ្នោតកន្លងមកនៅក្នុងប្រទេសកម្ពុជា គឺជាការមើលងាយទាំងស្រុងចំពោះឆន្ទៈរបស់អ្នកបោះឆ្នោតកម្ពុជា និងជាការបដិសេធនូវការពិត។ ការបោះឆ្នោតលើកទីមួយនៅឆ្នាំ១៩៩៣ ត្រូវបានផ្តួចផ្តើម និងរៀបចំដោយអង្គការសហប្រជាជាតិ។ ការបោះឆ្នោតនៅឆ្នាំ១៩៩៨ ត្រូវបានប្រធានក្រុមអ្នកសង្កេតការណ៍អាមេរិកចាត់ទុកថាជា «អព្ភូតហេតុដ៏អស្ចារ្យនៃដងទន្លេមេគង្គ»។ ការបោះឆ្នោតនៅឆ្នាំ២០១៣ត្រូវបានចាត់ទុកថាមានលក្ខណៈសេរីនិងយុត្តិធម៌ណាស់ ដោយគណបក្សប្រឆាំងបានកើន២៦អាសនៈ ហើយគណបក្សកាន់អំណាចបានបាត់បង់២៣អាសនៈ។ ស្ថានទូតអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ បានអំពាវនាវឱ្យគ្រប់គណបក្សនយោបាយទាំងអស់ទទួលយកលទ្ធផលនៃការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០១៧ ដោយរៀបរាប់ថាការបោះឆ្នោតមានសណ្តាប់ធ្នាប់និងពុំមានអំពើហិង្សា និងជាព្រឹត្តិការណ៍ដ៏សំខាន់មួយក្នុងការបន្តអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ការបោះឆ្នោតនៅឆ្នាំ២០១៨ បានប្រព្រឹត្តទៅដោយពុំមានអំពើហិង្សា មានសណ្តាប់ធ្នាប់ សេរីនិងយុត្តិធម៌ ដោយមានអ្នកចូលរួមបោះឆ្នោតរហូតដល់ ៨៣,០២% ទោះបីជាមានការអំពាវនាវរបស់ក្រុមក្រៅច្បាប់ឱ្យធ្វើពហិកាមិនចូលរួមក៏ដោយ។ តួរលេខនេះមិនត្រឹមតែបង្ហាញពីបំណងប្រាថ្នារបស់ប្រជាជនកម្ពុជាចង់ឃើញការបន្តនិរន្តរភាព ក្នុងមាគ៌ាប្រកបដោយសន្តិភាព ស្ថិរភាព ប្រជាធិបតេយ្យ និងនីតិរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញពីទំនុកចិត្តជាថ្មីរបស់ពួកគេ ចំពោះការដឹកនាំរបស់គណបក្សកាន់អំណាចក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីសម្រេចឱ្យបានគោលដៅទាំងនេះ។

- ការចាប់ខ្លួនលោក កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិ (CNRP) និងការរំលាយគណបក្សរបស់គាត់ដោយតុលាការកំពូល គឺត្រូវបានធ្វើឡើងដោយអនុលោមទាំងស្រុងទៅតាមច្បាប់ជាធរមានរបស់រដ្ឋអធិបតេយ្យមួយ ក្នុងស្មារតីថែរក្សាសន្តិភាព និងស្ថិរភាព ព្រមទាំងការការពារអធិបតេយ្យភាព និងឯករាជ្យភាពរបស់កម្ពុជា។ គាត់ត្រូវបានចោទប្រកាន់ពីបទសន្ទិដ្ឋិភាពជាមួយបរទេស ដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌកម្ពុជា(មាត្រា៤៤៣)។

- សេចក្តីព្រាងនៃ «ច្បាប់ប្រជាធិបតេយ្យកម្ពុជាឆ្នាំ ២០១៩» នេះ បានទំលាក់កំហុសទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ដែលតាមពិតទៅ ច្បាប់នេះមានដូចគ្នានៅក្នុងប្រទេសលោកខាងលិចជាច្រើន ដើម្បីធានាតម្លាភាព និងគណនេយ្យភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងនោះ។ ជាការពិត

ណាស់ ច្បាប់LANGO នេះ ត្រូវបានតាក់តែងឡើងដោយដកស្រង់បទពិសោធន៍ល្អៗជាច្រើន ចេញពីច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលរបស់ប្រទេសនានាដែលមានភាពចាស់ទុំខាង ប្រជាធិបតេយ្យ រួមមាន សហរដ្ឋអាមេរិកផងដែរ។ ច្បាប់នេះក៏មានអត្ថន័យស្របតាមមាត្រា ៤២នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា២០នៃសេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ២២នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិលនិងនយោបាយ។ ករណីវិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) គឺពាក់ព័ន្ធនឹងការខកខានមិនបានអនុវត្តតាមមាត្រា៣៤ នៃច្បាប់ស្តីពីសមាគមនិងអង្គការ មិនមែនរដ្ឋាភិបាល។

- សេចក្តីព្រាងច្បាប់នេះ រិះគន់ខុសអំពីការរឹតត្បិតសេរីភាពសារព័ត៌មាន និងប្រាសចាកឆ្ងាយពី ការពិត។ ការពិតនោះគឺ កាសែត និងបណ្តាញសារព័ត៌មានមួយចំនួនតូចប៉ុណ្ណោះដែលបាន ជ្រើសរើសតាមឆន្ទៈរបស់ខ្លួនក្នុងការបញ្ឈប់ប្រតិបត្តិការរបស់ពួកគេនៅពេលប្រឈមនឹង កាតព្វកិច្ចសារពើពន្ធ និងការរំលោភបំពានច្បាប់សារព័ត៌មានរបស់កម្ពុជា។ កម្ពុជាលើកកម្ពស់ យ៉ាងខ្លាំងនូវសេរីភាពសារព័ត៌មាននិងការបញ្ចេញមតិ ដោយឈរលើមូលដ្ឋាននីតិរដ្ឋ ដូច បានបង្ហាញតាមរយៈបរិយាកាសប្រព័ន្ធផ្សព្វផ្សាយយ៉ាងរស់រវើកនៃអង្គការកាសែត ទូរទស្សន៍ និង វិទ្យុ ដែលបានចុះបញ្ជីជាង១០០០ស្ថាប័ន កំពុងដំណើរការ ហើយមានការរិះគន់ចំពោះ រាជរដ្ឋាភិបាល។ ជាងនេះទៅទៀត ជាមួយនឹងទូរស័ព្ទចល័តដែលភ្ជាប់អ៊ីនធឺណិតជាង ១៣លាន៦សែនគ្រឿង នៅឆ្នាំ២០១៨ ប្រជាជនកម្ពុជារីករាយនឹងលទ្ធភាពទទួលបានព័ត៌មាន គ្មានដែនកំណត់ ឆាប់រហ័ស និងគ្មានការរឹតត្បិត ដែលរួមមានទាំងវិទ្យុអាស៊ីសេរី វិទ្យុសម្លេង សហរដ្ឋអាមេរិក (VOA) និងកាសែតឌឺខេមបូឌាដេលី ព្រមទាំងការចែករំលែកព័ត៌មានផ្ទាល់ ខ្លួនតាមអ៊ិនធឺណិត និងលើបណ្តាញសង្គមផ្សេងៗទៀតផងដែរ។

- សមាជិកសភាដែលស្នើច្បាប់នេះ ហាក់ដូចជាមើលរំលងការពិតជាក់ស្តែង ដែលរាជរដ្ឋាភិបាល កម្ពុជាបានឯកភាពតាមសំណើរបស់ស្ថានទូតអាមេរិកនៅភ្នំពេញ ចំពោះការផ្តល់ទិដ្ឋាការចូល និងស្នាក់នៅក្នុងប្រទេសកម្ពុជារយៈពេល១២ខែ ដល់អ្នកស្ម័គ្រចិត្ត Peace Corps នៅខែមករា កន្លងមកនេះ និងការអនុញ្ញាតិឱ្យបើកការិយាល័យតំណាងរបស់វិទ្យុVOA នៅកម្ពុជាឡើងវិញ នៅខែឧសភា ឆ្នាំ២០១៩។ នេះជាឧទាហរណ៍ពីរ ក្នុងចំណោមឧទាហរណ៍ជាច្រើនដែលបាន បង្ហាញឲ្យឃើញថាសេចក្តីព្រាងច្បាប់នេះបានពឹងផ្អែកលើព័ត៌មានចាស់ៗដែលហួសសម័យកាល។

- ដោយសារមានចេតនាអាក្រក់ ទើបសេចក្តីព្រាងច្បាប់នេះ មិនមានលើកចំណុចយោងណាមួយទាក់ទងទៅដល់រៅហាសាស្ត្រប្រជានិយមដ៏គ្រោះថ្នាក់របស់ក្រុមប្រឆាំងមួយចំនួននៅកម្ពុជា ដែលប្រើប្រាស់វិធីសាស្ត្រប្រមាថ និងបង្កាច់បង្ខូចមិនរើសមុខ អុចអាល បង្កការស្អប់ជាតិសាសន៍ និងការស្អប់ជនបរទេស បំផុសជាតិនិយមជ្រុល អំពាវនាវឱ្យយោធាប្រឆាំងនឹងរដ្ឋាភិបាល និងបំផ្លិចបំផ្លាញការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ ដែលទាំងអស់នេះ ត្រូវបានទទួលការស្អប់ខ្ពើមយ៉ាងខ្លាំងនៅក្នុងគ្រប់សង្គមប្រជាធិបតេយ្យនានា។ ការវាយតម្លៃដោយយុត្តិធម៌និងសត្យានុម័តអំពីសេរីភាពនយោបាយនិងសិទ្ធិមនុស្ស មិនត្រូវភ្លេចពីធាតុពិតនៃគណបក្សប្រឆាំងមួយដែលគ្មានលក្ខណៈគ្រប់គ្រាន់នោះទេ។ ជាងនេះទៅទៀត ប្រតិកម្មរបស់សហរដ្ឋអាមេរិកចំពោះការវិវត្តនយោបាយថ្មីៗនៅកម្ពុជា ហាក់ដូចជាមិនបានស្តែងចេញតាមរយៈគុណតម្លៃប្រជាធិបតេយ្យនោះទេ បើពិនិត្យទៅលើភាពខុសគ្នានៃនយោបាយរបស់សហរដ្ឋអាមេរិកជាមួយប្រទេសផ្សេងៗទៀត ពាក់ព័ន្ធនឹងបញ្ហាប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស។

៣. ខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះ កាន់តែបង្កការរំខានថែមទៀត នៅពេលដែលបុគ្គលសាធារណៈរបស់រដ្ឋអធិបតេយ្យមួយ បានក្លាយជាកម្មវត្ថុនៃវិធានការដាក់ទណ្ឌកម្មពីសំណាក់រដ្ឋមួយផ្សេងទៀត ដោយផ្អែកលើការចោទប្រកាន់គ្មានមូលដ្ឋាន។ នេះគឺជាការរំលោភបំពានយ៉ាងជាក់ស្តែងចំពោះគោលការណ៍អន្តរជាតិស្តីពីអធិបតេយ្យភាព សមភាព និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង ដូចមានចែងក្នុងមាត្រា២នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

៤. អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចាត់ទុកថា ការអនុម័តសេចក្តីព្រាងច្បាប់ខាងលើរបស់សភាសហរដ្ឋអាមេរិក ដើរផ្ទុយទៅនឹងកិច្ចខិតខំប្រឹងប្រែងដែលប្រទេសទាំងពីរកំពុងប្រកាន់យក ក្នុងការលើកកម្ពស់ភាពជាដៃគូគ្រប់វិស័យ ដោយផ្អែកលើផលប្រយោជន៍រួមនិងការគោរពគ្នាទៅវិញទៅមក។ ថ្វីបើមានសម្ពាធដ៏អយុត្តិធម៌ និងការដាក់ទណ្ឌកម្មជាឯកតោភាគីពីសំណាក់សហរដ្ឋអាមេរិកក្តី ក៏រាជរដ្ឋាភិបាលកម្ពុជាបានជ្រើសយកអភិក្រមវិជ្ជមានប្រកបដោយភាពស្មោះត្រង់ ក្នុងការបន្តកិច្ចសហប្រតិបត្តិការជាមួយសហរដ្ឋអាមេរិកលើវិស័យជាច្រើន ដូចជាបេសកកម្មមនុស្សធម៌ «ស្តង់ដារមាស» MIA/POW កម្មវិធីមាតុភូមិនិវត្តន៍យ៉ាងសកម្ម ការចាប់ផ្តើមឡើងវិញនូវកិច្ចសន្ទនាយោធា ការគាំទ្រដល់អ្នកស្ម័គ្រចិត្ត Peace Corps និងការប្រយុទ្ធរួមគ្នាយ៉ាងសកម្មប្រឆាំងនឹងការប្រឈមផ្នែកសន្តិសុខមិនប្រពៃណី (ភេរវកម្ម និងការជួញដូរ ជាដើម)។

៥. អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមសំដែងជាថ្មី នូវការប្តេជ្ញាចិត្ត ឥតងាករេរបស់កម្ពុជា ក្នុងការប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងលើកកម្ពស់នីតិរដ្ឋ និងការគោរពសេរីភាពជាមូលដ្ឋាន ស្របទៅតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជា។ លើសពីនេះទៀត អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទទូចដល់អង្គនីតិប្បញ្ញត្តិបរទេសទាំងអស់ រក្សានូវភាពឥតលំអៀងរបស់ខ្លួន និងចៀសវាងនូវសកម្មភាពមិនចាំបាច់នានាដែលមិនគោរពដល់ អធិបតេយ្យភាព និងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា៕

ថ្ងៃ អង្គារ ១៥កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៩